# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Aug-2013, 14:55
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង សាធារណៈ/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សំណើសុំបញ្ជីទាំងអស់ដែលមានការរៀបចំ និងតាមលំដាប់លំដោយ នៃរាល់ឯកសារដែលទទួលយកជាភស្តុតាងក្នុងសំណុំរឿង ០០២/០១

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

ព្រុំ ផល្លា

សួន វិសាល

Joshua ROSENSWEIG

Forest ONEILL GREENBERG

Elizabeth BUDNITZ

**ចម្លងជូន:**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា:**

ជា លាង

Andrew CAYLEY

**សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

សហមេធាវីការពារក្តី នួន ជា ("ក្រុមមេធាវីការពារក្តី") សូមដាក់ជូនសំណើជាបន្ទាន់ ស្នើសុំបញ្ជីឯកសារទាំងអស់ដែលបានបញ្ចូលក្នុងសំណុំរឿង ០០២/០១៖

1. នៅក្នុងអនុស្សរណៈផ្ញើជូនជាមុន ដែលបានផ្ញើជូនភាគីទាំងអស់ នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ ('អនុស្សរណៈ')។ អង្គជំនុំជម្រះ បាននិយាយថា៖

> នួន ជា បានធ្វើសំណើអោយអង្គជំនុំជម្រះ ផ្តល់បញ្ជីច្បាស់លាស់នៃឯកសារ E3។ ក្នុងការជូនដំណឹងស្តីពីការសម្រេចឯកសារលើកទី៣ (E185/2) និង សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ (E299) រួមជាមួយនឹងឧបសម្ព័ន្ធ អង្គជំនុំជម្រះបានចាត់ឯកសារជាលេខ E3 នូវរាល់ឯកសារទាំងអស់ដែលទទួលយកជាភស្តុតាងនៅក្នុងសំណុំរឿង ០០២/០១។ មុនពេលលេខទាំងអស់នោះត្រូវបានដាក់ចូលក្នុងZylab ភាគីទាំងអស់ គួរតែប្រើប្រាស់ចំណាត់ថ្នាក់ E3 ដែលបានចង្អុលបង្ហាញនៅក្នុងឧបសម្ព័ន្ធនៃឯកសារ E185/2 និង E299។ អង្គជំនុំជម្រះចាត់ទុកថា សំណើដែលនៅសល់ទាំងអស់នៅក្នុងឯកសារ E295/3 មានភាពជាន់គ្នានឹងសំណើរបស់ នួន ជា ពីមុន ដែលបានបង្ហាញក្នុងសេចក្តីសំរេចជាលាយលក្ខណ៍អក្សរ (E299)។ អង្គជំនុំជម្រះ ក៏ចង់រំលឹកដល់ភាគីទាំងអស់ថា គ្មានសំណើណាមួយ នឹងត្រូវបានធ្វើឡើងឡើយពាក់ព័ន្ធនឹងការទទួលយក និងតម្លៃទទួលយកជាភស្តុតាងនៃកំណត់ហេតុស្តាប់ចម្លើយសាក្សី[1]។

2. ក្រុមមេធាវីការពារក្តី កត់សម្គាល់ថា ជាដំបូង ក្រុមមេធាវីការពារក្តី នួន ជា មិនបានធ្វើសំណើសុំបញ្ជី "ច្បាស់លាស់" នៃឯកសារE3នោះទេ ប៉ុន្តែគឺក្រុមមេធាវីការពារក្តី ខៀវ សំផន ទេ ដែលជាអ្នកទាមទារបញ្ជីនោះម្តងហើយម្តងទៀត ដោយមិនមានការឆ្លើយតបច្បាស់លាស់ណាមួយពីអង្គជំនុំជម្រះនោះទេ[2]។ លើសពីនេះ ក្រុមមេធាវីការពារក្តីសង្កេតឃើញថា ការណែនាំរបស់អង្គជំនុំ

---

[1] អនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះ ផ្ញើទៅកាន់ភាគីទាំងអស់ តាមរយៈសារអេឡិចត្រូនិចពីលោក Ken Roberts ថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០១៣

[2] សូមមើលឯកសារលេខ E-295/2 'Nouvelle demade de la Defence de M. KHIEU Samphan de report du point de depart du delai de depot des conclusions finales' ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៣ កថាខណ្ឌ ៨, ១៣ ; ឯកសារលេខ E-

ជម្រះនៅក្នុងអនុស្សរណៈ នៅមានភាពមិនច្បាស់លាស់ ថាតើបញ្ជីនោះនឹងមានឬកអត់។ ជាពិសេស អនុស្សរណៈមិនបានបញ្ជាក់ថាតើ បញ្ជីនោះនឹងត្រូវបានផ្តល់ជូនភ្លាមៗ ពេលដែលលេខឯកសារថ្មីត្រូវបាន 'បញ្ជូនទៅ Zylab' នោះទេ។ ក្នុងករណីណាក៏ដោយ សំណើសុំបញ្ជីច្បាស់លាស់នៃលេខឯកសារ E3 នេះ មិនមានការពាក់ព័ន្ធនឹង 'សេចក្តីសំរេចជាលាយលក្ខណ៍អក្សរ (E299)' របស់អង្គជំនុំជម្រះនោះទេ។

3. ឯកសារដែលទទួលយកត្រូវបានដាក់ជាឧបសម្ព័ន្ធភ្ជាប់ទៅនឹងសេចក្តីសម្រេចនានាដោយអង្គជំនុំជម្រះនៅក្នុងអំឡុងពេលសវនាការ។ ឧបសម្ព័ន្ធខ្លះមានការបញ្ជាក់ច្បាស់លាស់ ប៉ុន្តែមួយចំនួនទៀតគឺជាការរួមផ្សំគ្នានៃឯកសារដែលស្នើសុំដោយភាគី ឬនៅពេលវេលាណាមួយ។ ឧបសម្ព័ន្ធផ្តល់ជូនដល់ភាគីជាទម្រង់ 'pdf' ដែលមិនអាចរៀបចំ ឬកំណត់ជាប្រភេទជាអេឡិចត្រូនិចបាន។ សំខាន់បំផុតនោះ បើទោះជារួមគ្នាក៏ដោយ ក៏ឧបសម្ព័ន្ធទាំងនេះមិនត្រូវបានយល់ថា ជាបញ្ជីឯកសារដែលត្រូវបានទទួលយកនោះទេ។ ឧទាហរណ៍ ឯកសារមួយចំនួនហាក់ដូចជាត្រូវបានចាត់ទុកជាឯកសារ E3 រួចមកហើយនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីដោយមិនបានរៀបរាប់ជាឧបសម្ព័ន្ធ[3]។ ដូចដែលសហព្រះរាជអាជ្ញាបានកត់សម្គាល់ក្នុងពេលថ្មីៗនេះថាឯកសារអាចត្រូវបាន "ធ្លាក់ក្នុងក្រហែង" ហើយមិនត្រូវចាត់ក្នុងប្រភេទឯកសារ E3 បើទោះជាអាចទទួលយកជាភស្តុតាងក៏ដោយ[4]។

4. ការមានបញ្ជី "ច្បាស់លាស់" នៃឯកសារ E3 ទាំងអស់គឺជាការសំខាន់មួយ។ ជាបឋម បញ្ជីនេះអាចឲ្យភាគីនូវការដឹងយ៉ាងច្បាស់លាស់ថា ឯកសារណាមួយត្រូវបានទទួលយកជាភស្តុតាង និងមិនមានការស្រពិចស្រពិលណាមួយ។ សម្រាប់ហេតុផលជាក់ស្តែងគឺថា ភាពពិតប្រាកដទាក់ទងនឹងភស្តុតាងដែលអង្គជំនុំជម្រះអាចពឹងផ្អែកក្នុងសេចក្តីសម្រេចរបស់ខ្លួនគឺមានសារៈសំខាន់ណាស់

---

288/2 'Observations de la Defence de M. KHIEU Samphan en vue de la reunion de mise en etat du 123 juin 2013" ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៣ កថាខណ្ឌ ២៣-២៤។

[3] *សូមមើល ដូចជា* E3/3988 រហូតដល់ E3/3994។

[4] ឯកសារលេខ **E-1/227.1** "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី" ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ 44:16-45:3។

ចំពោះសមត្ថភាពរបស់ភាគីក្នុងការសរសេរសេចក្តីសន្និដ្ឋានបិទ[5]។ ទីពីរ បញ្ជីនេះនឹងអាចជួយ នួន ជា នូវការយល់ឃើញដោយសង្ខេប និងទូលំទូលាយលើភស្តុតាង ដែលប្រការនេះសំខាន់ណាស់ ទៅលើសមត្ថភាពរបស់គាត់ក្នុងការពិគ្រោះជាមួយមេធាវី ដោយយោងទៅលើការផ្តង់អារម្មណ៍ របស់គាត់មានកម្រិត។ ហើយក៏ជាការជួយដូចគ្នាដល់មេធាវីជាតិ និងអន្តរជាតិ។ ទីបី បញ្ជីនេះនឹង សម្រួល និងពន្លឿនដំណើការព្រាង នៅពេលដែលការផ្លាស់ប្តូរនៅតែជាការចាំបាច់រវាងឯកសារ ដែលប្រើក្នុងពេលស៊ើបអង្កេត និង ឯកសារដែលចាត់ថ្នាក់ក្នុងពេលសវនាការ។

5. សម្រាប់ហេតុផលនេះ មេធាវីការពារក្តី សូមស្នើដោយគោរពដល់អង្គជំនុំជម្រះបញ្ជាក់ថា តើបញ្ជី ជាក់លាក់មួយនៃឯកសារទាំងអស់ដែលទទួលយកជាភស្តុតាងនឹងមានឬក៏អត់ និងចេញបញ្ជីដូច នេះដោយបញ្ជាក់ពីលេខឯកសារដើម និង លេខដែលចាត់ដោយអង្គជំនុំជម្រះក្នុងពេលសវនាការ។

**សហមេធាវី នួន ជា**

**សុន អរុណ** **Victor KOPPE**

[5] ឯកសារលេខ **E-295/3**, "សំណើសុំឲ្យធ្វើការបំភ្លឺពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយសាក្សី ពាក្យបណ្តឹង និងប្រតិចារិក និងការសុំពន្យារពេលវេលាសម្រាប់ការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល" ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៣។